មជ្ឈមណ្ឌលឯកសារកម្ពុជា

# របាយការណ៍

# ទីតាំងប្រល័យពូជសាសន៍ស្រុកសណ្តាន់ និងស្រុកប្រាសាទបល្ល័ង្ក

# ខេត្តកំពង់ធំ កាលពីថ្ងៃទី១៩ដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០២

ដោយៈ ផេង ពង្សរ៉ាស៊ី

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចំនួន៣រូបបានធ្វើដំណើរទៅកាន់ខេត្តកំពង់ធំ តាមបណ្តោយផ្លូវជាតិលេខ៦ ពីភ្នំពេញក្នុងចម្ងាយ១៦៨គីឡូម៉ែត្រ ។ គោលបំណងនៃការធ្វើដំណើរ គឺដើម្បីស្រាវជ្រាវនៅស្រុកសណ្តាន់ និងស្រុកប្រាសាទបល្ល័ង្កអំពីទីតាំងប្រល័យពូជសាសន៍នានាដែលបានកើតមានឡើងក្នុងជំនាន់ខ្មែរក្រហម ។

## ក) ស្រុកសណ្តាន់

ស្រុកសណ្តាន់ មានចម្ងាយ៨៩គីឡូម៉ែត្រពីទីរួមខេត្តកំពង់ធំ ។ ស្រុកនេះមានព្រំប្រទល់ខាងកើតជាប់នឹងស្រុកសៀមបុក ខេត្តស្ទឹងត្រែង និងស្រុកសំបូរ ខេត្តក្រចេះ, ខាងលិចជាប់នឹងស្រុកប្រាសាទបល្ល័ង្ក ខាងជើងជាប់នឹងស្រុករវៀង ខេត្តព្រះវិហារ និងខាងត្បូងជាប់នឹងស្រុកសន្ទុក ខេត្តកំពង់ធំ ។ មានឃុំចំនួន៩ជាចំណុះឲ្យស្រុក ។ ផ្លូវលំមួយខ្សែដែលតភ្ជាប់ពីប្រាសាទសំបូរណ៍ព្រៃគុបហ៍ឆ្ពោះទៅកាន់ស្រុកសណ្តាន់ មិនត្រូវបានធ្វើឡើងវិញឡើយ ។ នៅខែវស្សាស្រុកសណ្តាន់ត្រូវធ្វើដំណើរដោយទូក ។ ចំពោះខែប្រាំងវិញការធ្វើដំណើរទៅកាន់ស្រុកសណ្តាន់ត្រូវធ្វើដំណើរតាមផ្លូវគោកក្រហេងក្រហូងដោយរទេះសេះ ម៉ូតូ កង់ ថ្មើរជើង និងដោយប្រភេទរថយន្តសម្រាប់ប្រើក្នុងសង្គ្រាម ។ ថ្វីត្បិតតែការធ្វើដំណើរកាត់ព្រៃ កាត់បឹងបួរ និងកាត់វាល ស្រែរបស់ប្រជាជន ប៉ុន្តែពុំសូវបានប្រទះឃើញមានផ្ទះរបស់ប្រជាជនរស់នៅឡើយ ។ យូរៗទើបប្រទះឃើញ មនុស្សប្រុសៗពីរបីនាក់ ខ្លះមានលីកាំបិតលើស្មា ខ្លះលីចបឆ្ពោះទៅកាន់ដីស្រែរៀងៗខ្លួន ។ ភ្លឺស្រែជាច្រើន កន្លែងត្រូវបានរំលាយធ្វើជាផ្លូវសម្រាប់ឆ្លងកាត់ និងធ្វើជាផ្លូវវាងស្ពានទ្រុឌទ្រោម ។ ខ្ញុំភ័យស្ទើរលោះព្រលឹង មួងៗនៅរាល់ការឆ្លងកាត់ស្ពានដែលមានតែសរសរជ្រុងពីរដើមដាក់សណ្តូកឆ្លងកាត់បឹង និងអូរពីត្រើយម្ខាងទៅត្រើយម្ខាងទៀត ។ ក្រៅពីរថយន្តអង្គការទស្សនៈពិភពលោកមួយ, រថយន្តឈ្នួលមួយ និងរថយន្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលថ្មីតែម៉ាស៊ីនមួយគ្រឿងទៅ គឺសង្កេតឃើញមានតែរទេះសេះ ម៉ូតូនិងកង់ប៉ុណ្ណោះដែលធ្វើដំណើរប្រុយៗតាមផ្លូវដ៏លំបាកនេះ ។ ខ្លួនខ្ញុំត្រូវប្រឡាក់ដីស្រម៉ក ដោយសារតែកាយដីខ្សាច់ក្រាស់ៗធ្វើផ្លូវរថយន្ត និងធ្វើជាព្រួសម្រាប់តម្រង់ផ្លូវ ។ ក្នុងចម្ងាយជាង៨០គីឡូម៉ែត្រ រថយន្តដឹកញ្ញាស់មួយគ្រឿង

នេះ បានប្រើរយៈពេលអស់ជាង៩ម៉ោង ។ ការធ្វើដំណើរលើកនេះ ខ្ញុំបានក្លាយទៅជាអ្នកស៊ីឈ្នួលរុញឡាន ដោយមិនយកប្រាក់កម្រៃជាញឹកញាប់ និងក្លាយជាអ្នកជួយ(គ្រីបឡាន) មួងម្កាលក្នុងពេលរថយន្តជាប់ខ្សាច់ ។

ក្នុងគម្រោងស្រាវជ្រាវរយៈពេលពីរថ្ងៃនៅស្រុកសណ្ដាន់ ក្រុមស្រាវជ្រាវយើងបានប្រើពេលហួសមួយថ្ងៃកន្លះថែមទៀត ដោយសារតែការបន្តឡើងពីរថយន្តដែលចេះតែមានបញ្ហា ។ ទោះជាយ៉ាងនេះក៏ដោយ ក្រុមស្រាវជ្រាវទាំងបីនាក់នៅតែបន្តការធ្វើដំណើរដោយម៉ូតូឌុបចំនួនពីរគ្រឿងឆ្ពោះទៅកាន់ទីតាំងសម្ងាប់ និងមន្ទីរសន្តិសុខព្រៃកន្ទៀង ដែលមានចម្ងាយប្រមាណ២០គីឡូម៉ែត្រពីកន្លែងឡានដែលទៅមិនបាន ។

១) មន្ទីរសន្តិសុខព្រៃកន្ទៀង

លេខកូដភូមិសាស្ត្រៈ០៦០៦០១

រយៈកំពស់ **(N) 13º 05' 03:77"**

រយៈទទឹង **(E) 105º 15' 34:00"**

ព្រៃឈើធំៗមួយកន្លែងដែលស្ថិតនៅក្នុងភូមិព្រៃកន្ទៀង ឃុំសុចិត្ត ស្រុកសណ្ដាន់ បានក្លាយទៅជាបរិវេណនៃមន្ទីរសន្តិសុខស្រុកសណ្ដាន់តាំងពីឆ្នាំ១៩៧០ ។ ព្រៃនេះមានចម្ងាយប្រហែល៣គីឡូម៉ែត្រពីផ្លូវទៅកាន់សាលាស្រុកសណ្ដាន់ប៉ែកខាងត្បូង ។ មន្ទីរសន្តិសុខ ត្រូវបានបង្កើតឡើងដើម្បីឃុំឃាំងប្រភេទប្រជាជនមូលដ្ឋានដែលរឹងរូសមិនព្រមបញ្ជូនកូនចៅរបស់ខ្លួនឲ្យចូលបម្រើក្នុងជួរបដិវត្តន៍កាលពីឆ្នាំ១៩៧១ ។ លោក សៅ យឿន អតីតប្រធានធម្មការស្រុកសណ្ដាន់បានរំលឹកថា នៅឆ្នាំ១៩៧០ចលនាឃោសនាមួយបានកើតឡើងនៅក្នុងស្រុកសណ្ដាន់ ។ ការឃោសនានេះបានធ្វើឡើងដោយឈ្មោះ ហង់ ដែលបានអះអាងខ្លួនឯងថា ជាអ្នកតស៊ូដើម្បីទាមទារសម្ដេចឪឲ្យចូលស្រុកវិញ ។ មិនយូរប៉ុន្មាន ការហូរចូលនៃប្រជាជនភាគច្រើនទៅខាងបក្សរបស់សមមិត្ត ហង់ បានចំនួន៩០ភាគរយនៃប្រជាជនទាំងអស់នៅក្នុងស្រុកសណ្ដាន់ ។ ការកសាងកម្លាំងរបស់ សមមិត្ត ហង់ បានឈានទៅដល់ការជោគជ័យមួយយ៉ាងសម្បើម ។ ដោយសារតែមានកម្លាំងល្មមគ្រប់គ្រាន់ ហើយសមមិត្ត ហង់ បានចាប់ផ្ដើមអនុវត្តនយោបាយគៀបសង្កត់មកលើប្រជាជនដែលមិនទាន់សម្រេចចិត្តចូល ធ្វើបដិវត្តន៍ ។ មន្ទីរសន្តិសុខព្រៃកន្ទៀងបានក្លាយទៅជាផ្ទះរួមនៃអ្នកដែលស្ទាក់ស្ទើរក្នុងការសម្រេចចិត្តចូល បដិវត្តន៍ទាំងនោះ ដែលប្រកបទៅដោយទារុណកម្មយ៉ាងអស្ចារ្យ ។ សៅ យឿន បានមានប្រសាសន៍បន្តថា មេភូមិ-មេឃុំមួយចំនួនត្រូវបានធ្វើទារុណកម្មរហូតដល់ស្លាប់ ដោយសារតែមានកំហុសឃាត់ឃាំងក្នុងការចូលបម្រើបដិវត្តន៍ ។ ភាពចលាចលផ្សេងៗបានកើតមាននៅក្នុងទូទាំងស្រុកសណ្ដាន់ ។ ការផ្លាស់ប្ដូរសមត្ថភាពនៃបណ្ដាសមមិត្ត ក៏សង្កេតឃើញកើតមានឡើងជារើយៗ ។ សមមិត្ត ហង់ ត្រូវជំនួសដោយសមមិត្ត អ៊ុន

ក្នុងការកាន់កាប់មន្ទីរសន្តិសុខព្រៃកន្ទែង និងក្រោយមកទៀតមានសមមិត្ត ប៉ាន់ សមមិត្ត ណៃ និងសមមិត្ត គៀន ។

ក្រោយថ្ងៃរំដោះ១៧ មេសា ឆ្នាំ១៩៧៥ មានទាហានលន់ ណុល ជាច្រើនបានត្រូវដឹកយកមកសម្លាប់ចោលគ្មានសល់នៅក្នុងទឹកដីឃុំសណ្តាន់ត្រង់ម្តុំបឹងធំ ភូមិស្រែចង់ ។ ហេតុការណ៍នេះបានធ្វើឲ្យរំជើបរំជួលដល់អ្នកដែលផប់ផល់នឹងសម្តេចសីហនុជាខ្លាំងថាមានការរន្ធោះរន្ធើនិងប្រេះស្រាំ ។ ខាងខ្មែរក្រហមដែលសៅ យឿន ថាបានដើរលឿនមុនមួយជំហាននៃអ្នកស្នេហាខាងសម្តេចសីហនុនោះ បានប្រមែប្រមូលខ្សែស្រឡាយ និងក្រុមញាតិសណ្តានខាង ហ៊ូ យន់ និងហ៊ូ នឹមយកទៅសម្លាប់នៅក្នុងព្រៃកន្ទែងទាំងអស់ ។ តាំងពីឆ្នាំ១៩៧៦មក មន្ទីរសន្តិសុខនេះបានទទួលស្វាគមន៍ដល់អ្នកចំណូលថ្មីដូចជាប្រជាជនជម្លៀស(១៧មេសា) មកពីទីក្រុងភ្នំពេញ និងទីរួមខេត្តកំពង់ធំ ប្រជាជនមូលដ្ឋាន កម្មាភិបាលខ្មែរក្រហមដែលបាននិយាយជំទាស់នឹងបញ្ជារបស់បដិវត្តន៍ ។ល ។ អ៊ួង កាំង អាយុ៦៦ឆ្នាំ បាននិយាយថាប្រជាជន១៧មេសាទាំងអស់បានត្រូវយកទៅផ្ញើតាមសហករណ៍នានាក្នុងស្រុកសណ្តាន់ ។ វាសនានៃអ្នក១៧មេសានោះ ត្រូវបានកម្ទេចម្តងបន្តិចៗរហូតដល់អស់តាមរយៈនៃការឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខព្រៃកន្ទែង ។ ទៃ អ៊ួន អាយុ៥៦ឆ្នាំ បានប្រាប់ថាគាត់បានឃើញខ្មែរក្រហមបណ្តើរមនុស្សស្ទើរតែរាល់ថ្ងៃចូលក្នុងមន្ទីរឃុំឃាំងព្រៃកន្ទែងនេះ ពេលដែលគាត់កំពុងឡើងត្នោត ។ ជួនកាល អ៊ួន បានស្គាល់ច្បាស់ថាជាប្រជាជនដែលរស់នៅភូមិទឹកម្លាង ឃុំសណ្តាន់ បានត្រូវចងស្លាបសេកបណ្តើរដោយខ្មែរក្រហមប្រដាប់ដោយអាវុធអាការចូលមកកាន់មន្ទីរឃុំឃាំង ។ ពេលខ្លះ អ៊ួន បានជួបនឹងកងសន្តិសុខវ័យក្មេងៗដែលយកឡេសថាដើររកគោដែលបានវង្វេងបាត់ទៅ ។ ប៉ុន្តែធាតុពិត អ៊ួន បានប្រាប់ថា «គ្រាន់តែជាការបញ្ឆោតភ្នែកយើងទេ តាមពិតវាដើររកចាប់មនុស្សទៀតហ្នឹង» ។ ទោសកំហុសគ្រប់យ៉ាងត្រូវបានបញ្ជូនមកដាក់នៅក្នុងមន្ទីរសន្តិសុខព្រៃកន្ទែង ហើយជីវិតអ្នកទាំងនោះ មិនត្រូវបានរួចខ្លួនពីសេចក្តីស្លាប់ឡើយ ។ ប្រជាជនមូលដ្ឋានដែលបានមកជាប់នៅក្នុងមន្ទីរសន្តិសុខព្រៃកន្ទែងនេះ បានត្រូវរាយការណ៍មកថា ធ្លាប់បានប្រព្រឹត្តខុសនឹងវិន័យរបស់អង្គការបក្ស ដូចជាខុសសីលធម៌ លួចនេះ លួចនោះ ខ្ជិលច្រអូសច្រើន ។ល ។ មន្ទីរសន្តិសុខព្រៃកន្ទែង មានហ៊ុំព័ទ្ធទៅដោយរបងបន្លាលួសយ៉ាងក្រាស់ឃ្មឹកដែលមិនងាយនឹងចេញបានឡើយ ។ អ៊ួង កាំង និយាយពីការដឹកថ្នាំអង់ទ្រីនចូលទៅកាន់ផ្ទះសន្តិសុខមួយដែលស្ថិតនៅក្បែរមន្ទីរសន្តិសុខធំថា បានឃើញលួសបន្លារាយជាច្រើនជាន់ព័ទ្ធជុំវិញមន្ទីរ និងមានផ្ទះសម្រាប់កងសន្តិសុខស្នាក់នៅជាហូរហែរជាប់របងនៃមន្ទីរសន្តិសុខនោះ ។

តាមការបំភ្លឺរបស់ អ៊ួង កាំង និង ទៃ អ៊ួន ថានៅមានកងសន្តិសុខមួយចំនួននៅរស់នៅឡើយ ។ កងសន្តិសុខទាំងនោះគឺៈ

១) ស្រស់ ជាគ្រូបង្រៀននៅសាលាបឋមសិក្សាតាំងក្រសៅ ភូមិស្រឡៅ(ចារពៅ) ឃុំងន ស្រុកសណ្ដាន់ ខេត្តកំពង់ធំ ។

២) ខ្មៀ រស់នៅភូមិបាជ័យ ឃុំសណ្ដាន់ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ ។

៣) ជា សុខ រស់នៅភូមិអន្លង់ស្វែង ឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ។

២) ទីតាំងសម្លាប់ព្រៃកន្លែង

លេខកូដភូមិសាស្ត្រៈ ០៦០៦០២

រយៈកំពស់ **(N) 13º 05' 06:38"**

រយៈទទឹង **(E) 105º 15' 22:84"**

ទីតាំងសម្លាប់មួយកន្លែង ស្ថិតនៅក្រៅបរិវេណមន្ទីរសន្តិសុខព្រៃកន្លែងប្រមាណ៣០០ម៉ែត្រ ។ ក្នុងចន្លោះនៃទីតាំងសម្លាប់និងមន្ទីរសន្តិសុខ មានមន្ទីរសួរចម្លើយមួយកន្លែងដែលប្រដាប់ដោយតុសម្រាប់សរសេរ កំណត់ហេតុនៃចម្លើយសារភាព, ខ្សែពួរសម្រាប់ព្យួរមនុស្សសួរចម្លើយ, និងឃើញមានដំបងឈើមួយចំនួន ទៀតដែលមានស្នាមឈាមប្រឡាក់ពេញ ។ ក្នុងរចនាសម្ពន្ធ័នៃការសម្លាប់មនុស្សនៅព្រៃកន្លែង ខ្មែរក្រហមបាន បញ្ជូនអ្នកទោសទៅកន្លែងសួរចម្លើយ ហើយបន្ទាប់មកទៀតទើបបញ្ជូនទៅកាន់កន្លែងសម្លាប់ ។ ការដដឹកយកចម្លើយបានធ្វើឡើងគ្រប់អ្នកទោសទាំងអស់មុននឹងយកទៅសម្លាប់ ។ អ្នកសួរចម្លើយ ត្រូវសួរតាមការកំណត់របស់អង្គការ ។ ឯអ្នកឆ្លើយវិញដាច់ខាតត្រូវឆ្លើយតាមសំណួរដែលបានសួរទោះជាខ្លួនមិនបានប្រព្រឹត្តិក៏ដោយ ។ ទៃ អួន បាននាំក្រុមស្រាវជ្រាវទៅពិនិត្យមើលកន្លែងសួរចម្លើយកាលពីជំនាន់ខ្មែរក្រហម ព្រមទាំងបានបង្ហាញពីរបៀបចងជើងអ្នកទោសព្យួរឡើងលើ និងទំលាក់ចុះមកវិញ.......... ។ ឧបករណ៍សួរចម្លើយនានាត្រូវទុកចោលនៅនឹងកន្លែង ពេលដែលកងទ័ពរណសិរ្សនិងកងទ័ពវៀតណាមចូលមកដល់ ។ រហូតមកដល់សព្វថ្ងៃ មន្ទីរសួរចម្លើយមិនបានបន្សល់ទុកនូវវត្ថុតាងអ្វីបន្តិចសោះឡើយសម្រាប់ធ្វើការកត់សម្គាល់ ប៉ុន្តែយ៉ាងហោចណាស់ក៏កន្លែងនោះ បានក្លាយទៅជាដីកម្មសិទ្ធរបស់លោក អួង កាំង ជាសមាជិកនៃក្រុមប្រឹក្សាឃុំសណ្ដាន់ ស្រុកសណ្ដាន់ ។ បច្ចុប្បន្ន កាំង បានដាំដើមស្វាយមួយដើមនៅចំកន្លែងដែលព្យួរអ្នកទោសសួរចម្លើយ ។ ចំណែកឯជ្រុងខាងជើងឈៀងខាងកើតប្រហែលជាង២០០ម៉ែត្រនៃដីរបស់គាត់គឺជាទីតាំងសម្លាប់ មនុស្សរបស់ខ្មែរក្រហម ។ ជនរងគ្រោះដែលត្រូវបានសម្លាប់នៅទីនោះគឺប្រភេទជនរងគ្រោះដែលបានយក ចេញពីមន្ទីរសន្តិសុខព្រៃកន្លែង និងបានឆ្លងកាត់ការសួរចម្លើយ ។ អួង កាំង បន្តថានៅក្នុងព្រៃនៃចម្ការរបស់ គាត់មានសុទ្ធតែក្បាលខ្មោចដែលសេសសល់ពីជ្រូកព្រៃស៊ី ។ ទៃ អួន បានប្រាប់ថា កាលពីឆ្នាំ១៩៨៣ ខាងសាលាស្រុកបាននាំគ្នាមកប្រមូលឆ្អឹងលលាដ៏ក្បាល

និងគាស់យកឆ្អឹងដែលនៅក្នុងដីទៅតម្កល់ទុកនៅវត្តទឹក ម្នាង ហើយក្រោយមកបានផ្លាស់ប្តូរទីកន្លែងទៀត ។ មានរណ្តៅជាង២០ ដែលក្នុងមួយរណ្តៅៗមានសាកសព ពី៤-៥នាក់ ។ ក្រោយពីដីនេះធ្លាក់ក្នុងការកាន់កាប់ដោយ អួន កាំង មកគាត់ក៏បានត្រួសត្រាយព្រៃ និងរានដីសម្រាប់ធ្វើចម្ការ ។ ក្នុងពេលត្រួសត្រាយនោះ កាំង បានពើបប្រទះឃើញឆ្អឹងយ៉ាងច្រើនទៀត ដែលភាគខ្លះនៃឆ្អឹងនៅមានជាប់ចំណងនៅឡើយ ។ កាំង បានសន្និដ្ឋានថាដីរបស់គាត់ត្រង់ណាក៏មានខ្មោចងាប់ដែរកាលពីជំនាន់ខ្មែរក្រហម ។

ចំណែកឯកងចល័តស្រុកមួយចំនួនធំ ក៏ត្រូវបាននាំយកមកសម្លាប់នៅក្នុងបរិវេណព្រៃកន្លែងនេះដែរ ។ ទៃ អួន បានប្រាប់ពីការសម្លាប់កងចល័តស្រុកថា ពេលដែលគាត់ធ្វើជាប្រធានកងដឹកជញ្ជូននៅកងចល័តស្រុក គាត់ចេះតែឆ្ងល់ថាហេតុអ្វីបានជាសមាជិកក្រុមរបស់គាត់ចេះតែបាត់ទៅៗ ។ ក្រោយមកទើបគាត់ដឹងថាអ្នកដែលបាត់ខ្លួននោះ គឺត្រូវបានសម្លាប់ទាំងអស់ ។

ការសម្លាប់មនុស្សនៅព្រៃកន្លែងបានប្រព្រឹត្តិទៅរហូតដល់ចុងឆ្នាំ១៩៧៨ ។ ឯវិធីសម្លាប់គឺខ្មែរក្រហម បានប្រើដំបង និងព្រនង់ជាឧបករណ៍សម្លាប់ ។ ទៃ អួន ប្រាប់ថាក្រោយបែកឆ្នាំ១៩៧៩ គាត់បានដើរមក បោចវល្លិ៍ជាមួយបងប្អូនជីដូនមួយគាត់ម្នាក់ ក៏បានឃើញមានដំបង និងព្រនង់ប្រឡាក់សុទ្ធតែឈាមមនុស្សស្អិត នៅគរបោលក្បែរកន្លែងសម្លាប់ និងកន្លែងសួរចម្លើយ ។

## ២) ស្រុកប្រាសាទបល្ល័ង្គ

ស្រុកប្រាសាទបល្ល័ង្គ ជាស្រុកដែលទើបតែបង្កើតថ្មីនៅឆ្នាំ១៩៩១ ។ ស្រុកនេះមានចំនួន៧ឃុំ និង៦៥ភូមិ ។ កាលពីជំនាន់ខ្មែរក្រហមគឺជាស្រុក៧៣ តំបន់៤៣ ។ ស្រុកនេះមានព្រំប្រទល់ខាងជើងជាប់នឹងខេត្តព្រះវិហារ ខាងត្បូងជាប់នឹងស្រុកកំពង់ស្វាយ ខាងលិចជាប់នឹងស្រុកស្ទោង និងខាងកើតជាប់នឹងស្រុកប្រាសាទសំបូរណ៍ ។ ផ្ទៃដីរួមនៃស្រុកគឺ ១២៩,៣៦០ ហិកតា ដោយបែងចែកជាដីបង្កបង្កើនផលចំនួន១៧,៦៩៦ ហិកតា ។ ដីស្រែប្រាំងចំនួន១០ហិកតា ។ ស្រែវស្សាចំនួន ១០, ៣២៤ ហិកតា ។ ដីចម្ការចំនួន ១,៣៧២ ហិកតា ។ ដីទំនេរចំនួន ២៧,២៩២ ហិកតា និង ដីព្រៃចំនួន ៩០,៩៧២ ហិកតា ។ ស្រុកប្រាសាទបល្ល័ង្គ ជាស្រុកមួយដែលមានផ្ទៃដីធំទូលាយ និងមានឃុំមួយចំនួនដែលជាចំណុះនៃស្រុកស្ថិតនៅដាច់ស្រយ៉ាលពីទីរួមស្រុក ។ ឃុំទួលគ្រើល ជាឃុំមួយដែលមានចម្ងាយជាង២០គីឡូម៉ែត្រពីសាលាស្រុកប្រាសាទបល្ល័ង្គ ។ ការធ្វើដំណើរត្រូវឆ្លងកាត់ព្រៃភ្នំ ដងស្ទឹង និងទីទំនាប ។ ឃុំនេះ ជាគោលដៅនៃការចុះស្រាវជ្រាវលើកនេះ ។ មានបង្គោលថ្មប្លុនជ្រុងដែលទើបនឹងដាំថ្មី ព្រមជាមួយអក្សរខ្មែរដែលបញ្ជាក់ពីទីតាំងដែលបានដោះមីនរួចជាច្រើនកន្លែងនៅតាមដងផ្លូវខ្សាច់ដែលកំពុងធ្វើដំណើរ ។ អ្នករត់ម៉ូតូឌុបបាននិយាយថា ប៉ុន្មានឆ្នាំមុនគ្មាននរណាហ៊ាន

ចូលតាមព្រៃនេះទេ ។ កាលពីឆ្នាំ១៩៩៨ ក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះមកម្តងរួចហើយនៅស្រុកប្រាសាទបល្ល័ង្កនេះ ប៉ុន្តែត្រូវបានហាមឃាត់មិនឲ្យធ្វើដំណើរទៅកាន់ឃុំទួលគ្រើលនេះទេ ដោយសារមូលហេតុមិនទាន់មានការដោះមីន ។ ទើបតែពេលនេះ (ថ្ងៃ២២ ខែកុម្ភៈ ឆ្នាំ២០០២) បានហ៊ានធ្វើដំណើរទៅកាន់ទីនោះដោយស្ងៀមស្ងាត់ ។

១) ទីតាំងសម្លាប់ត្រពាំងក្រសាល

លេខកូដភូមិសាស្ត្រៈ ០៦០៨០២

រយៈកំពស់ **(N) 13º 01' 41:47"**

រយៈទទឹង **(E) 104º 47' 53:05"**

ត្រពាំងក្រសាល គឺជាកន្លែងសម្លាប់មនុស្សកាលពីជំនាន់ខ្មែរក្រហម ។ កន្លែងនេះស្ថិតនៅដាច់ស្រយាល ពីភូមិអ្នកស្រុកប្រហែលជាង៣គីឡូម៉ែត្រ ។ ការធ្វើដំណើរទៅកាន់ទីនោះត្រូវឆ្លងកាត់តាមផ្លូវដែលគ្មានមនុស្ស ដើរ និងមានសភាពស្ងាត់គួរព្រឺយរារម្ភ ។ អ្នកភូមិជន្ទុសស្ទើរតែគ្រប់គ្នាសុទ្ធតែមិនដែលបានទៅដល់មុំត្រពាំង ក្រសាលនេះទេ ដោយមូលហេតុខ្លាចខ្មែរក្រហមដែលមិនទាន់បានផ្តាច់ខ្លួន ។ ម្យ៉ាងទៀតក្នុងចន្លោះពីភូមិជន្ទុសទៅកាន់ត្រពាំងក្រសាលគឺជាដែនដីដែលកាន់កាប់ដោយទាហានខ្មែរក្រហមកាលពីទសវត្សន៍ទី៨០ និងដើមទសវត្សន៍ទី៩០ ។ ប៉ុន្តែក្រោយពេលរដ្ឋាភិបាលធ្វើសមាហរណកម្មកាលពីឆ្នាំ១៩៩៨មក ទាហានខ្មែរក្រហមទាំងនោះត្រូវចាកចេញពីទីនោះមករស់នៅក្នុងភូមិស្រុកជាមួយប្រជាជនធម្មតាវិញ ដោយប្រែក្លាយទៅជាទីវាលរហោដ្ឋានគ្មានមនុស្សនៅ ។ ម៉ូតូចំនួន៤គ្រឿងបានជូនខ្ញុំទៅដល់សំណល់រណ្តៅដ៏ធំមួយ និងស្លាកស្នាមរណ្តៅមួយចំនួនទៀតដែលស្ថិតនៅក្បែរគ្នា ។ ប្រធានឃុំទួលគ្រើលឈ្មោះ ព្រាប ហាវ បាននិយាយប្រាប់ព្រមទាំងចង្អុលថា «នេះជារណ្តៅដាក់ខ្មោចកាលពីជំនាន់ខ្មែរក្រហម ដែលសុទ្ធតែជាប្រជាជន១៧មេសា ហើយសុទ្ធតែប្រុសៗ ទៀត» ។ ប្រជាជនមូលដ្ឋានចាស់ម្នាក់ឈ្មោះ នង រី អាយុ៤៩ឆ្នាំ ជាអតីតអ្នកលាយលាមកគោនៅក្នុងភូមិ ជន្ទុស ឃុំទួលគ្រើលបានប្រាប់ថា ខ្លួនបានដឹងយ៉ាងច្បាស់ពីការសម្លាប់មនុស្សនៅត្រពាំងក្រសាលនេះ ។ តូច ថី អាយុ៤៩ឆ្នាំ បានបញ្ជាក់ដូចស្រាយ ឆាងដែរថា ប្រជាជន១៧មេសាទាំងអស់ដែលបានបញ្ជូនមកពីទីរួម ខេត្តកំពង់ធំ និងទីក្រុងភ្នំពេញមួយចំនួន ត្រូវសម្លាប់ដោយមិនបានសាកសួរអ្វីទាំងអស់បន្ទាប់ពីបានដាក់ឲ្យជាប្រជាជនបញ្ញើហើយនោះ ។ ចំណែកប្រជាជនមូលដ្ឋានវិញ មានមួយចំនួនត្រូវបានបញ្ជូនទៅកាន់មន្ទីរសន្តិសុខនីពេជ្រ ដែលជាមន្ទីរសន្តិសុខប្រចាំស្រុកកំពង់ស្វាយពីបទរឹងទទឹង និងលួចដំឡូងហូប ។ មានប្រជាជនច្រើន

ណាស់បានស្លាប់ដោយសារការបង្អត់អាហារ និងជម្ងឺ ។ រណ្តៅសាកសពចំនួន១ដែលមានទទឹងប្រហែល២ម៉ែត្រ និងបណ្តោយប្រហែល៤ម៉ែត្រ បានត្រូវដឹងព្សស្ទើរតែគ្រប់គ្នាពីប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិជន្ទុស ឃុំទួលគ្រើលថាជារណ្តៅដែលបានសម្លាប់មនុស្សកាលពីជំនាន់ខ្មែរក្រហម ។ ការរំលឹកឡើងវិញដោយសារការស្រាវជ្រាវនេះ បានធ្វើឲ្យប្រជាពលរដ្ឋទាំងនោះភ្ញាក់ម្ទឹម្នាឡើងវិញនឹកឃើញរឿងរ៉ាវកាលពីជំនាន់ខ្មែរក្រហមថាបានសម្លាប់បងប្អូន កូនចៅរបស់ខ្លួន និងសម្លាប់ប្រជាជន១៧មេសាដែលជម្លៀសពីទីក្រុងទាំងគ្មានកំហុសអ្វីបន្តិចសោះ ។ ក្រៅពីរណ្តៅដែលបានបន្សល់ស្លាកស្នាមនោះទៅ នៅមានរណ្តៅមួយចំនួនទៀតដែលគ្មានបានបន្សល់នូវអ្វីបន្តិចទាល់តែសោះ ។ សាកសពរាប់រយនាក់បានត្រូវសម្លាប់ដោយខ្មែរក្រហមក្នុងអំឡុងឆ្នាំ១៩៧៥ដល់១៩៧៩ ។ អដ្ឋិធាតុមិនត្រូវបានគាស់ឡើយរហូតមកដល់ពេលនេះ ។ ដើមថ្កុង ដើមត្បែង និងដើមឈើដទៃទៀតបានដុះចាក់ប្រជ្រៀតគ្នានៅពីលើ និងនៅក្បែររណ្តៅសាកសពស្ទើរដើរចូលមិនរួច ។ សត្វគោ-ក្របីទាំងហ្វូងៗ បាននាំគ្នាមកដណ្តើមស៊ីស្មៅនៅជុំវិញបរិវេណរណ្តៅសាកសពនេះ ។ នៅខែវស្សា រណ្តៅមួយនេះបានក្លាយទៅជាកន្លែងផ្ទុកទឹកពេញប្រៀបសម្រាប់ផឹកនៃពពួកសត្វទាំងនោះ ។

យូរៗទើបឃើញមានមនុស្សដើរកាត់

បរិវេណនេះម្តងក្នុងអារម្មណ៍ភ័យខ្លាចព្រលឹងខ្មោចដែលបានស្លាប់នៅក្នុងរណ្តៅនេះតាមលង ។

**២) ទីតាំងសម្លាប់ភូមិឈើទាល**

លេខកូដភូមិសាស្ត្រ: ០ ៦ ០ ៤ ០ ៣

រយៈកំពស់ **(N) 12º 59' 53:36"**

រយៈទទឹង **(E) 104º 49' 12:36"**

ភូមិដែលគ្មានមនុស្សម្នារស់នៅនាពេលបច្ចុប្បន្ននេះដែលស្ថិតនៅក្នុងឃុំទួលគ្រើល ស្រុកប្រាសាទបល្ល័ង្ក មានឈ្មោះហៅថា ភូមិឈើទាល ។ ដីទួលមួយខ្ពស់ជាងគេ ដែលមានដើមឈើផ្សេងៗដុះយ៉ាងក្រាសឃ្មឹកនោះត្រូវបានសម្គាល់ជាទីកំណើតនៃអ្នកស្រុកមួយចំនួនដែលបានផ្លាស់ប្តូរទីលំនៅបន្ទាប់ពីមានការដេញចេញដោយខ្មែរក្រហម ហើយមិនត្រឡប់ទៅរស់នៅភូមិនេះវិញនៅពេលដែលប្រទេសកម្ពុជាបានជួបប្រទះនឹងភាពសន្តិភាពពេញបរិបូរណ៍ហើយនោះ ។ ភូមិដែលមានតែឈ្មោះអត់មនុស្សរស់នៅនេះ បានក្លាយជាទីលានសម្លាប់មនុស្សប្រភេទប្រជាជន១៧មេសា ។ ផ្ទះសម្បែងមួយចំនួនត្រូវបានបំផ្លាញ និងមួយចំនួនទៀតត្រូវយកធ្វើជាផ្ទះសម្រាប់ការស្នាក់នៅនៃកងឈ្លបខ្មែរក្រហម ។ ប្រជាជន១៧មេសារាប់រយនាក់ បានត្រូវសម្លាប់នៅភូមិឈើទាល ។ ភាគច្រើននៃជនរងគ្រោះគឺជាប្រុសៗដែលបានចាញ់បញ្ឆោតខ្មែរក្រហមថាឲ្យទៅរៀនសូត្រ ។ ឆាយ ឆូ អាយុ៥០ឆ្នាំ រស់នៅភូមិថ្នល់ ឃុំទួលគ្រើល ស្រុកប្រាសាទបល្ល័ង្កប្រាប់ថា ធ្លាប់បានឃើញកងឈ្លប

ខ្មែរក្រហមបណ្ដើរជនរងគ្រោះមកសម្លាប់តែ១ដងគត់ដែលមានគ្នាប្រហែលជា៣០នាក់សុទ្ធតែចងដៃទៅក្រោយខ្នង ។ ការបណ្ដើរនេះ ឆាយ នួ បានឃើញនៅពេលព្រលប់ៗពេលដែលគាត់ត្រឡប់មកពីធ្វើការវិញ ។ ឆាយ នួ បានកំណត់នៅក្នុងចិត្តរបស់គាត់ថា ជនរងគ្រោះទាំងនោះពិតជាត្រូវយកទៅសម្លាប់នៅភូមិឈើទាលមិនខាន ព្រោះគ្មានកន្លែងណាផ្សេងឡើយ ។ ក្នុងអារម្មណ៍ភ័យខ្លាច នួ មិនបាននៅចាំលបមើលឡើយ ។ លុះមកដល់ក្រោយឆ្នាំ១៩៧៩ នួ បានទៅមើលដោយផ្ទាល់ភ្នែក ក៏ស្រាប់តែប្រទះឃើញមានរណ្ដៅសាកសពចំនួន ៤ ធំៗ ។ រណ្ដៅធំៗទាំង៤នោះ ត្រូវបានគាស់ដើម្បីរកមាសពេជ្រដែលនៅជាប់នឹងខ្លួនសាកសព ។ ឆ្អឹងយ៉ាងច្រើនបានត្រូវបោះចោលយ៉ាងអាក្រាត់អាក្រាយលាយជាមួយលលាដ៏ក្បាលជាច្រើននៅលើដីមាត់រណ្ដៅ ។ ៦ រណ្ដៅទាំង៤ក៏មិនត្រូវបានលុបវិញដែរ ។ រហូតមកដល់បច្ចុប្បន្ន ឆ្អឹងទាំងប៉ុន្មានត្រូវបំផ្លាញដោយសត្វស៊ីអស់រលីង បន្សល់ទុកតែរណ្ដៅដែលមានជម្រៅរាក់ៗបីបួនប៉ុណ្ណោះ ។ តាមការឲ្យដឹងពីប្រធានឃុំទួលគ្រើល ព្រាប ហាវ ថាមានជនរងគ្រោះចំនួនរាប់រយនាក់បានមកស្លាប់នៅភូមិឈើទាលនេះ ។

ស្រុកមិនទាន់ស្រាវជ្រាវ

- ស្រុកស្ទោងៈ មានពីរទីតាំងគឺ

១) **អ្នកតាស្នាយ** ជាមន្ទីរសន្តិសុខ និង

២) **ទីតាំងសម្លាប់ក្បែរ មាត់ទន្លេសាប ។**

តាមការសាកសួរពីបណ្ដាប្រជាពលរដ្ឋមួយចំនួនបានឲ្យដឹងថា ទីតាំងទាំងពីរនេះត្រូវចំណាយពេល៣ថ្ងៃសម្រាប់ការស្រាវជ្រាវ(២ថ្ងៃសម្រាប់ការធ្វើដំណើរ និង១ថ្ងៃសម្រាប់ធ្វើការងារ) ។ ការធ្វើដំណើរមិនអាចយករថយន្តទៅបានទេ គឺធ្វើដំណើរតាមម៉ូតូកាត់ផ្លូវខ្សាច់ ។

សន្និដ្ឋាន

ការចុះទៅស្រាវជ្រាវនៅខេត្តកំពង់ធំនាដើមឆ្នាំ២០០២ជាលើកដំបូងនេះ ក្រុមស្រាវជ្រាវបានជួបបញ្ហាលំបាកច្រើនពីរឿងរថយន្ត និងផ្លូវធ្វើដំណើរ ។ ម្យ៉ាងទៀតទីតាំងដែលត្រូវចុះទៅស្រាវជ្រាវក្នុងឆ្នាំនេះសុទ្ធសឹងជាទីតាំងដែលក្រុមស្រាវជ្រាវទៅមិនដល់ដោយសារបញ្ហាផ្លូវលំបាកខ្លាំង, គ្មានផ្លូវ, អសន្តិសុខ(មីន និង ចោរប្លន់) ។ល ។ ចំពោះការប៉ាន់ស្មានពេលវេលាក៏ដូច្នេះដែរ ត្រូវតែមានពេលវេលាមួយសមរម្យសម្រាប់ការស្រាវជ្រាវទីតាំងឆ្ងាយៗដែលពោរពេញទៅដោយភាពលំបាកលំបិនច្រើន ដូចក្នុងករណីស្រុកសណ្ដាន់និងស្រុកប្រាសាទបល្ល័ង្កដែលយើងបានជួបប្រទះអញ្ចឹង ។ ទោះជាមានការលំបាកខ្លះៗក៏ដោយ ក៏ក្រុមស្រាវជ្រាវយើងនៅតែពុះពាររាល់ឧបសគ្គទាំងអស់ ដើម្បីភាពជោគជ័យក្នុងការស្រាវជ្រាវ ។

លទ្ធផលនៃការស្រាវជ្រាវ ក្រុមស្រាវជ្រាវបានទទួលលទ្ធផលជាផ្លែផ្កាគួរជាទីពេញចិត្ត ។ តាំងពីឆ្នាំ១៩៧០រហូតមកដល់ឆ្នាំ១៩៧៩ ប្រជាជនដែលរស់នៅក្នុងស្រុកសណ្ដាន់បានជួបប្រទះនូវសោកនាដកម្មយ៉ាងសម្បើមពីអ្នកកាន់អំណាចដែលអនុវត្តគោលនយោបាយផ្ដាច់ការ ។ សិទ្ធិសេរីភាពគ្រប់បែបយ៉ាងត្រូវបានហាមឃាត់សម្រាប់ប្រជាពលរដ្ឋ ។

ការឃោសនាអូសទាញកម្លាំងបានលេចរូបរាងឡើងយ៉ាងព្រោងព្រាតនៅតាមភូមិឃុំនានាក្នុងស្រុកតាមរយៈនៃការលើកឡើងតាមបែបស្ដេចនិយម ។ ប្រជាពលរដ្ឋមួយចំនួនបានត្រូវស្លាប់ដោយសារតែរឿងមិនយល់តាមកាលៈទេសៈ និងរឹងទទឹងច្រើនហួសពេក ។ ព្រៃកន្លែងបានក្លាយទៅជាមន្ទីរឃុំឃាំងសម្រាប់ប្រជាជនទាំងនោះ និងក្រោយមកក្លាយទៅជាមន្ទីរសន្តិសុខប្រចាំស្រុកសណ្ដាន់ទាំងមូល ។ តាំងពីឆ្នាំ១៩៧៥រហូតមកដល់ឆ្នាំ១៩៧៩ មន្ទីរនេះមានឃុំឃាំងជនរងគ្រោះគ្រប់ប្រភេទទាំងប្រជាជន១៧មេសា ប្រជាជនមូលដ្ឋាន អ្នកលួច អ្នកខុសសីលធម៌ កម្មាភិបាលដែលខុសឆ្គងៗល ។ អ្នកទោសដែលជាប់នៅក្នុងមន្ទីរសន្តិសុខនេះមិនត្រូវបានរួចខ្លួនពីសេចក្ដីស្លាប់ឡើយ ។ ឯការសម្លាប់វិញ ស្ថិតនៅកន្លែងសួរចម្លើយ និងកន្លែងកប់ផ្ទាល់តែម្ដងដែលមានចម្ងាយពីមន្ទីរសន្តិសុខប្រហែលជាង៣០០ម៉ែត្រប៉ែកខាងលិច ។ រណ្ដៅដែលបានគាស់រួចមានចំនួនជាង២០ និងមានអដ្ឋិធាតុយ៉ាងច្រើនសន្ធឹក ។ តាមការប៉ាន់ស្មានគឺមានចំនួនសាកសពរួមរាប់រយនាក់ ។

ចំណែកនៅឯស្រុកប្រាសាទបល្ល័ង្គ មានទីតាំងសម្លាប់ពីរកន្លែងស្ថិតនៅក្នុងឃុំទួលគ្រើលគឺ ត្រពាំងក្រសាំង និងភូមឈើទាល ។ ទីតាំងសម្លាប់ទាំងពីរកន្លែងនេះ ខ្មែរក្រហមបានសម្លាប់ភាគច្រើនបំផុតគឺប្រជាជន១៧មេសាដែលបានជម្លៀសចេញពីទីក្រុងភ្នំពេញនិងទីរួមខេត្តកំពង់ធំ ។ សាកសពរាប់រយនាក់ដែលបានស្លាប់នៅទីតាំងទាំងពីរនេះមិនត្រូវបានគាស់យកអដ្ឋិធាតុទៅតម្កល់ទុកឡើយ ។ ប៉ុន្តែបែរជាមានការគាស់រកមាសពេជ្រទៅវិញ ។ ឆ្អឹងដែលបានបោះគរនៅលើដីមាត់រណ្ដៅ បានត្រូវបំផ្លាញដោយសត្វគោក្របីស៊ីអស់ ។ រហូត មកដល់បច្ចុប្បន្ននៅមានស្លាកស្នាមខ្លះៗដូចជា មានជារូបរាងរណ្ដៅដែលមានស្មៅនិងដើមឈើផ្សេងៗដុះ គ្របពីលើ ។ ម្យ៉ាងទៀតជាទីតាំងដែលស្ថិតនៅឆ្ងាយដាច់ស្រយ៉ាលពីប្រជាជនផង ៕